ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៨ លេខ ២៤ ត្រីមាសទី ០១ ឆ្នាំ ២០១៨

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម


១០-០៣-២០១៨ -ព្រះរាជក្រម នស/រកម/០៣១៨/០០៥ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី វិសោធនកម្ម មាត្រា ២៦ មាត្រា ២៧ ថ្មី មាត្រា ២៨ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ២៩៦៣


### ២. ព្រះរាជក្រឹត្យ


១៦-០២-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០២១៨/១៧៦ ស្តីពី ការរំសាយដែនជម្រកសត្វព្រៃស្នួល ស្ថិតក្នុងខេត្តក្រចេះ និងការរំសាយដែនជម្រកសត្វព្រៃរនាមដូនសំ ស្ថិតក្នុងខេត្តបាត់ដំបង ២៩៧០

០៦-០៣-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៣១៨/២៦៣ ស្តីពី ការតែងតាំងឯកឧត្តម **អ៊ុំ សំអាត** ជាអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២៩៧២

០៦-០៣-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៣១៨/២៦៤ ស្តីពី ការតែងតាំងឯកឧត្តម **ឈួន វ៉ាន់** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ២៩៧៣

០៦-០៣-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៣១៨/២៦៥ ស្តីពី ការបញ្ចប់មុខតំណែង និងឋានៈឯកឧត្តម **ឡុង សុភ័ក្រ** ពីទីប្រឹក្សាឯកឧត្តម **អ៊ឹម សួស្តី** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ រដ្ឋលេខាធិការ ការតម្លើងឋានៈ តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម លោកជំទាវ ចំនួន ០២ រូប ជាទីប្រឹក្សាឯកឧត្តម **អ៊ឹម សួស្តី** ២៩៧៤

០៦-០៣-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៣១៨/២៦៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយឧត្តមសេនីយ៍ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ២៩៧៥

០៦-០៣-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៣១៨/២៦៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១៩ រូប ២៩៧៦

| | | |
|---|---|---|
| ០៦-០៣-២០១៨ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៨/២៦៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៧ រូប | ២៩៧៨ |
| ០៦-០៣-២០១៨ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៨/២៦៩ ស្តីពី និយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ចំនួន ០៥ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងពាណិជ្ជកម្ម | ២៩៧៩ |
| ០៦-០៣-២០១៨ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៨/២៧០ ស្តីពី ការតម្លើងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការ ចំនួន ០៥ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង | ២៩៨០ |
| ០៦-០៣-២០១៨ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៨/២៧១ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហាន (នារី) ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១៧ រូប | ២៩៨១ |


## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


| | | |
|---|---|---|
| ២៩-១២-២០១៧ | -អនុក្រឹត្យលេខ ២៥៧ អនក្រ.បក ស្តីពី ការផ្ទេរគណទានថវិកា | ២៩៨៣ |
| ០២-០៣-២០១៨ | -អនុក្រឹត្យលេខ ២៩ អនក្រ.បក ស្តីពី ការបង្កើតមូលនិធិធានាឥណទានកម្ពុជា | ២៩៨៥ |
| ១២-០៣-២០១៨ | -អនុក្រឹត្យលេខ ៣៨ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៩៦៤,៦៤ ហិកតា នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ ចេញពីដីតម្រុយព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋចំនួន ១០៧ គ្រួសារ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី | ២៩៩៤ |
| ០៧-០២-២០១៨ | -អនុក្រឹត្យលេខ ១៣៣ អនក្រ.តត ស្តីពី ការបន្ថែមសមាសភាពគណៈកម្មាធិការជាតិដឹកនាំតម្រង់ទិសការងារអគ្រានុកូលដ្ឋាន ស្ថិតិអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម | ២៩៩៨ |
| ០៩-០៣-២០១៨ | -អនុក្រឹត្យលេខ ២៨៧ អនក្រ.តត ស្តីពី ការផ្ទេរយោធិនពលី | ៣០០០ |
| ០៩-០៣-២០១៨ | -អនុក្រឹត្យលេខ ២៨៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៣០០២ |
| ០៩-០៣-២០១៨ | -អនុក្រឹត្យលេខ ២៨៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៣០០៣ |
| ០៩-០៣-២០១៨ | -អនុក្រឹត្យលេខ ២៩០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៣០០៥ |
| ០៩-០៣-២០១៨ | -អនុក្រឹត្យលេខ ២៩១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៣០០៦ |

១២-០៣-២០១៨ -អនុក្រឹត្យលេខ ២៩២ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៣០០៨
១២-០៣-២០១៨ -អនុក្រឹត្យលេខ ២៩៣ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៣០១០
១២-០៣-២០១៨ -អនុក្រឹត្យលេខ ២៩៤ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៣០១២
១២-០៣-២០១៨ -អនុក្រឹត្យលេខ ២៩៥ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ និងតែងតាំងឋានន្តរសក្តិមន្ត្រីនគរបាលជាតិ ៣០១៤
១២-០៣-២០១៨ -អនុក្រឹត្យលេខ ២៩៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣០១៥

## ២~សេចក្តីសម្រេច

១៤-០៣-២០១៨ -សេចក្តីសម្រេចលេខ ១៧ សសរ ស្តីពី ការបង្កើតគណៈកម្មការសម្រាប់កំណត់សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ហ្វ្រេកង់ស៍ ៧០០ MHz ៣០៤៦
១៥-០៣-២០១៨ -សេចក្តីសម្រេចលេខ ១៨ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៣០៤៨

## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៥-០២-២០១៨ -ប្រកាសលេខ ១៣០ សហវ.ប្រក ស្តីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៨ របស់អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៣០៤៩

### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

២៦-០៩-២០១៧ -ប្រកាសលេខ ៤៧៣ ឧស.កឧ.ប្រក ០៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ុនយ៉ាង លេបីល (ខេមបូឌា) អិលធីឌី បង្កើតសាខារោងចក្រ ផលិតស្លាកសញ្ញាសម្លៀកបំពាក់គ្រប់ប្រភេទ ៣០៥៥
២៦-០៩-២០១៧ -ប្រកាសលេខ ៤៧៤ ឧស.កឧ.ប្រក ០៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាប៊ូជី (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កែច្នៃដែកថែប ៣០៥៨
២៦-០៩-២០១៧ -ប្រកាសលេខ ៤៧៥ ឧស.កឧ.ប្រក ០៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេវើ-ស៊ុនើជី (ខេមបូឌា) ហ្គាម៉ិន ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣០៦១
២៦-០៩-២០១៧ -ប្រកាសលេខ ៤៧៦ ឧស.កឧ.ប្រក ០៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឡៃថឹ វីលដេខ័ររេសិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិត និងផ្គុំខ្សែអំពូលភ្លើងពិណលំអគ្រប់ប្រភេទ ៣០៦៤

# ព្រះរាជក្រម

នស/រកម/០៣១៨/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៩៣/០០១/២០១៨ កបធ.ច ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

មាត្រា ២៦ មាត្រា ២៧ថ្មី មាត្រា ២៨ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ និងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ ២០០៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា២៦.១.-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយ ឬរបស់បេក្ខជន ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនរបស់ខ្លួន។ បណ្តឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ យ៉ាងយូរបន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

ក្នុងករណីដែលរដ្ឋសភា ត្រូវបានរំលាយមុនផុតអាណត្តិ សាមីខ្លួនឬសាមីគណបក្សនយោបាយ អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញជាបន្ទាន់។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះជាបន្ទាន់ ។

សវនាការ ឬផ្នែកមួយនៃសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលវិនិច្ឆ័យលើបណ្តឹងតវ៉ាត្រូវធ្វើជាចំហ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបិទផ្សាយថ្ងៃ ខែ ឆ្នាំ ទីកន្លែង និងពេលវេលានៃការបើកសវនាការវិនិច្ឆ័យលើបណ្តឹងតវ៉ានេះ ។

**មាត្រា២៦.២.-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់បុគ្គល ឬតំណាងចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបដិសេធបណ្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោតរបស់ខ្លួន។ បណ្តឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបាន សេចក្តីចម្លង សេចក្តីសម្រេចពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចលើបណ្ដឹងតវ៉ានេះដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលបានពាក្យបណ្ដឹង ។

**មាត្រា២៦.៣.-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ា ឬជំទាស់ជាលាយលក្ខណ៍អក្សររបស់បុគ្គល ឬតំណាង ចំពោះសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាអំពីការបាត់បង់ឈ្មោះ ឬលើការជំទាស់អំពីការចុះឈ្មោះ ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃបុគ្គលម្នាក់ដែល មានលក្ខណៈមិនត្រឹមត្រូវតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត ។ បណ្ដឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលបានសេចក្ដីចម្លងសេចក្ដីសម្រេចបដិសេធពីគណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្ដឹងតវ៉ា ឬជំទាស់នេះ ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបានពាក្យបណ្ដឹង។

**មាត្រា២៦.៤.-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ាដោយផ្ទាល់ ជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយ ដែលបានឈរឈ្មោះបោះឆ្នោត ចំពោះលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន ។ បណ្ដឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្ដឹងតវ៉ា ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេលពី ១០ (ដប់)ថ្ងៃ ទៅ ២០ (ម្ភៃ) ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលបានពាក្យបណ្ដឹង។

**មាត្រា២៦.៥.-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់បុគ្គល ឬគណបក្សនយោបាយ ចំពោះសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធបណ្ដឹងតវ៉ាអំពីលទ្ធផលបោះឆ្នោតបណ្ដោះអាសន្នរបស់ខ្លួន។ បណ្ដឹងនេះត្រូវបានធ្វើឡើង ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីការបដិសេធ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្ដឹងតវ៉ានេះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេលពី ១០(ដប់)ថ្ងៃ ទៅ ២០ (ម្ភៃ) ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលបានពាក្យបណ្ដឹង។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា២៦.៦.-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់បុគ្គល ដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានចែងក្នុងជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជំពូកទី១០ (ទោស ប្បញ្ញត្តិ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ បណ្តឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីកាលបរិច្ឆេទ ទទួលបានសេចក្តីសម្រេចនេះ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេល ១០(ដប់)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានពាក្យបណ្តឹងតវ៉ា។

**មាត្រា២៦.៧.-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ផ្សេងទៀត ដែលបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា កំណត់ថាជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

**មាត្រា២៧.-ថ្មី(ពីរ)**

១-បណ្តឹងតវ៉ា ឬជំទាស់ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលសម្រេចបដិសេធការតវ៉ា ឬការជំទាស់ត្រូវធ្វើឡើងដោយដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ។

នៅក្នុងលិខិតនៃពាក្យបណ្តឹង ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ ៖

ក- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង។ ក្នុងករណីអ្នកប្តឹងជាគណបក្សនយោបាយ ឈ្មោះ និងអាសយដ្ឋានព្រមទាំងឋានៈរបស់បុគ្គលដែលធ្វើសកម្មភាពបណ្តឹងក្នុងនាមគណបក្សនយោបាយ

ខ- សញ្ញាណនៃសេចក្តីសម្រេច និងសេចក្តីដែលប្តឹងតវ៉ា ឬជំទាស់ចំពោះសេចក្តីសម្រេចនេះ

គ- មូលហេតុនៃការប្តឹងតវ៉ា ឬប្តឹងជំទាស់

ឃ- ភស្តុតាងដែលត្រូវពិនិត្យដើម្បីបញ្ជាក់អំពីមូលហេតុនៃការប្តឹងតវ៉ា ឬប្តឹងជំទាស់។

២-បណ្តឹងតវ៉ាដោយផ្ទាល់ អំពីលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន ត្រូវធ្វើដោយដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

នៅក្នុងលិខិតនៃពាក្យបណ្តឹងត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

ក- ឈ្មោះ និងអាសយដ្ឋានរបស់គណបក្សនយោបាយ និងឈ្មោះ និងអាសយដ្ឋាន ព្រមទាំងឋានៈ របស់បុគ្គលដែលធ្វើសកម្មភាពបណ្តឹង ក្នុងនាមគណបក្សនយោបាយនោះ

ខ- ឈ្មោះ និងអាសយដ្ឋាន និងឋានៈរបស់ភាគីម្ខាងទៀតនៃបណ្តឹង

គ- ខ្លឹមសារនៃការទាមទារ

ឃ- អង្គហេតុដើម្បីបញ្ជាក់នូវការទាមទារ

ង- ភស្តុតាងដែលត្រូវពិនិត្យដើម្បីបញ្ជាក់អំពីអង្គហេតុខាងលើ។

៣-បណ្តឹងរបស់បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយអនុលោមតាមបទប្បញ្ញត្តិជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅក្រុមក្រុមប្រឹក្សាធម្មនុញ្ញ ។

នៅក្នុងលិខិតនៃពាក្យបណ្តឹង ត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

ក- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹងតវ៉ា

ខ- ខ្លឹមសារនៃការទាមទារ

គ- សញ្ញាណនៃសេចក្តីសម្រេចដែលប្តឹងតវ៉ា

ឃ- មូលហេតុនៃការទាមទារ

ង- ភស្តុតាងដែលត្រូវពិនិត្យ ដើម្បីបញ្ជាក់អំពីមូលហេតុនៃការទាមទារ ។

បណ្តឹងដែលប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ មិនតម្រូវឲ្យបង់ប្រាក់ទេ ។

## មាត្រា២៨..ថ្មី

ក្នុងករណីបណ្តឹងមានលក្ខណៈផ្ទុយច្បាប់ ហើយចំណុចខ្វះខាតមិនអាចកែតម្រូវបានទេក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចលើកបណ្តឹងចោល ដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផល ។

ក្នុងករណីដែលពាក្យបណ្តឹងមិនបានសរសេរនូវចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង ហើយមិនព្រមកែតម្រូវតាមការបង្គាប់ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចលើកបណ្តឹងចោល។

យោងតាមករណីនីមួយៗ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចដោយឆ្លងកាត់ការសាកសួរតទល់ ឬការពិភាក្សាដេញដោល ។

## មាត្រា៣១..ថ្មី

ក្រោយពីបានទទួលពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវប្រគល់សិទ្ធិទៅឲ្យក្រុមណាមួយទទួលខុសត្រូវធ្វើការស៊ើបអង្កេត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

តាមតម្រូវការចាំបាច់ ក្រុមដែលទទួលខុសត្រូវនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅអ្នកប្ដឹងដោយកំណត់អំឡុងពេលសមស្របមួយ និងបង្គាប់ឲ្យកែតម្រូវនូវចំណុចខ្វះខាត ដែលត្រូវសរសេរក្នុងលិខិតនៃពាក្យបណ្ដឹង។ ករណីដែលអ្នកប្ដឹងមិនបានកែតម្រូវក្នុងអំឡុងពេលដែលបានកំណត់នោះ បណ្ដឹងត្រូវលើកចោលដោយក្រុមប្រឹក្សាធម្មនុញ្ញ។

តាមតម្រូវការចាំបាច់ ក្រុមដែលទទួលខុសត្រូវនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅកាន់អ្នកដែលត្រូវគេប្ដឹង ដោយកំណត់អំឡុងពេលសមស្រប។

**មាត្រា៣២.-ថ្មី**

ក្រោយពីបានទទួលលិខិតឆ្លើយតបរបស់អ្នកដែលត្រូវគេប្ដឹង ឬក្រោយផុតអំឡុងពេលកំណត់ និងក្រោយពីធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ហើយ ក្រុមដែលទទួលបន្ទុកត្រូវដាក់លទ្ធផលនៃការស៊ើបអង្កេត ព្រមទាំងយោបល់របស់ក្រុមនេះជូនក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់ប្រជុំពេញអង្គ ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចធ្វើការស៊ើបអង្កេតបន្ថែមទៀត ហើយអាចស្ដាប់អ្នកប្ដឹងតវ៉ា និងអ្នកដែលត្រូវគេប្ដឹងតវ៉ាដោយផ្ទាល់បាន ។

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃ សៅរ៍ ៩រោច ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៨

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្ដីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

៣រស. ១៨០៣.២៥៣

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**ហត្ថលេខា**
**អង្គ វង្សវឌ្ឍានា**

លេខៈ ៣២០ ស.ណ
**សំណៅដែលមានអង្គរជាការចែកផ្សាយ**
ថ្ងៃអង្គារ ១២កើត ១៨ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៨/១៧៦

ស្ដីពី

## ការរំសាយដែនជម្រកសត្វព្រៃស្នួល ស្ថិតក្នុងខេត្តក្រចេះ និងការរំសាយដែនជម្រកសត្វព្រៃរនាមដូនសំ ស្ថិតក្នុងខេត្តបាត់ដំបង

យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដែលបានកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៥៣ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- អនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

- បានទ្រង់យល់សេចក្តីបង្គំទូលថ្វាយរបស់អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ .-**

ត្រូវបានរំសាយដែនជំរកសត្វព្រៃស្នួលដែលមានផ្ទៃដីចំនួន៧៥.០០០ហិកតា ចេញពីព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដែលបានកំណត់តំបន់ការពារធម្មជាតិ។

**មាត្រា២ .-**

ត្រូវបានរំសាយដែនជំរកសត្វព្រៃនាមជូនសំដែលមានផ្ទៃដីចំនួន៣៩.៩៦១ហិកតា ចេញពីព្រះរាជក្រឹត្យ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ ដែលបានកែសំរួលផ្ទៃដីតំបន់ដែនជំរកសត្វព្រៃនាមជូនសំ។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សុក្រ ១កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារស.១៨០២.១៣៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**ហត្ថលេខា**
**សាយ សំអាល់**

លេខ:២២២ស.ណ
**សំណៅចែកមានតម្លៃជាការចែកផ្សាយ**
ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៨/៧៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស /រកម/ ០៩១៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **អ៊ុំ សំអាត** ជាអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៨*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

[illegible]

លេខ:២៩៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃសុក្រ ៨កើត ១២ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៨/២៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ឈួន ច័ន់** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៨*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ចារស.១៨០៣.២៦៤

លេខ: ២៩២ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៨/២៦៥

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ៣ឆ្នាំ លើកទី៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : បញ្ចប់មុខតំណែង និងឋានៈ ឯកឧត្តម **ឡុង សុភ័ក្រ** ពីទីប្រឹក្សាឯកឧត្តម **អ៊ឹម សូស្តី** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា២** : ដំឡើងឋានៈឯកឧត្តម **ម៉ក់ ផូល** ពីទីប្រឹក្សាឯកឧត្តម **អ៊ឹម សូស្តី** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ទៅជាទីប្រឹក្សាមានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា៣** : តែងតាំងនិងផ្តល់ឋានៈលោកជំទាវ **នង សុម៉ាលីកា** ជាទីប្រឹក្សាឯកឧត្តម **អ៊ឹម សូស្តី** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា៤** : ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ ២០១៨

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ចារស. ១៥០៣.២៦៩

លេខ: ២៩០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជក្រឹត្យ**

នស/រកត/០៣១៨/២៦៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** ៖ ដំឡើងឋានន្តរស័ក្តិ **នាយឧត្តមសេនីយ៍** ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- ឯកឧត្តមឧត្តមសេនីយ៍ឯក **ចោង សំអាត** អត្តលេខ ០៤៩៣

២- ឯកឧត្តមឧត្តមសេនីយ៍ឯក **ប៉ោ គក្កិ** អត្តលេខ ៥៤៨៦២ ។

**មាត្រា ២** ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៨*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ហត្ថលេខា និងព្រះរាជលញ្ចករ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខ:២៧៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃសុក្រ ៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

ទានស.១៨០៣.២៧០

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៨/២៦៧

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** ៖ ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- ឧត្តមសេនីយ៍ត្រី **ហុង ម៉ិនហ៊ាង** អត្តលេខ ០៣៧១
២- ឧត្តមសេនីយ៍ត្រី **សេង ជា** អត្តលេខ ០៩៣៧
៣- ឧត្តមសេនីយ៍ត្រី **ម៉ូរ ណ្ហាន** អត្តលេខ ០១២៣៣
៤- ឧត្តមសេនីយ៍ត្រី **ហ៊ីង សុភាព** អត្តលេខ ០១៣១២
៥- ឧត្តមសេនីយ៍ត្រី **ឃិត្យ សុភាព** អត្តលេខ ០១៣៣៧
៦- ឧត្តមសេនីយ៍ត្រី **ទុំ សុទ្ធី** អត្តលេខ ០១៨១៨
៧- ឧត្តមសេនីយ៍ត្រី **អ៊ុក ធីរៈ** អត្តលេខ ០៣៧៤២

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៨- ឧត្តមសេនីយ៍ត្រី **ឃិន លីម** អត្តលេខ ០៤៣០៤

៩- ឧត្តមសេនីយ៍ត្រី **យុន ឧុឌ្ឍី** អត្តលេខ ០៥០១៥

១០- ឧត្តមសេនីយ៍ត្រី **គូ ជាឡុង** អត្តលេខ ០៥៤៣០

១១- ឧត្តមសេនីយ៍ត្រី **អ៊ុង សុគី** អត្តលេខ ០៥៨០៩

១២- ឧត្តមសេនីយ៍ត្រី **សុខ ណុម** អត្តលេខ ០៦០៦៤

១៣- ឧត្តមសេនីយ៍ត្រី **ខៀវ គារុណ** អត្តលេខ ០៦២៥៩

១៤- ឧត្តមសេនីយ៍ត្រី **គុជ គន្ធថេន** អត្តលេខ ០៦៧៦៨

១៥- ឧត្តមសេនីយ៍ត្រី **អ៊ឹង ហាម** អត្តលេខ ០៩៩៦០

១៦- ឧត្តមសេនីយ៍ត្រី **សឿង ណុល** អត្តលេខ ១៥៧៦៧

១៧- ឧត្តមសេនីយ៍ត្រី **ហួន សុផល** អត្តលេខ ១៦០២៩

១៨- ឧត្តមសេនីយ៍ត្រី **ម៉ុង ប៉ក់** អត្តលេខ ១៦០៣៧

១៩- ឧត្តមសេនីយ៍ត្រី **ហ៊ួរ មិថុនា** អត្តលេខ ៣៦៨៤៤ ។

**មាត្រា ២ ៖** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៨*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានឃើញ ១៨០៣.២៧១

លេខៈ២៩៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៨/២៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ :

**ក. ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ**

| | | | |
|---|---|---|---|
| ១- ឧត្តមសេនីយ៍ត្រី | **ជួន សារ៉ាណ្ណ** | អត្តលេខ | **០៦៨៨៥** |
| ២- ឧត្តមសេនីយ៍ត្រី | **ចេង សេរីវុឌ្ឍ** | អត្តលេខ | **០២២៨៣** |
| ៣- ឧត្តមសេនីយ៍ត្រី | **លីម តេកឆេង** | អត្តលេខ | **៥៦១១១** |

**ខ. ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី**

| | | | |
|---|---|---|---|
| ១- វរសេនីយ៍ឯក | **យិន សាម៉ន** | អត្តលេខ | **១២៤៨៩** |
| ២- វរសេនីយ៍ឯក | **ឈឹម យ៉ាដាមូនី** | អត្តលេខ | **១៣០២៧** |
| ៣- វរសេនីយ៍ឯក | **គីង សុធី** | អត្តលេខ | **៥៤៣២៥** |
| ៤- វរសេនីយ៍ឯក | **ស៊ិន សុខាបុត្ត** | អត្តលេខ | **៥៧៣៥១** ។ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បរស. ១៥០៣. ២៧២

លេខ: ២៩៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា ឆព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

## ព្រះរាជក្រឹត្យ

នស/រកត/០៣១៨/២៦៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : និយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការចំនួន ០៥ រូប នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១ | លោក **ចាន់ សុខនី** | ពីរមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២ | លោក **ឡាយ សុខសៅគន្ធា** | ពីរមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣ | លោក **ហេង ណាន** | ពីរមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤ | លោក **ជា រីន** | ពីរមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៥ | លោក **គីម ច័ន្ទរស្មី** | ពីរមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៨

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បរណ. ១៥០៣.២៧៣

លេខ: ២៩៥ ស.ណ

**សំណៅដែលមានអង្គ្លេខាការចែកផ្សាយ**

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៨/២៧០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ NS/KRT-34 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដំឡើងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការ ចំនួន ០៥ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ចាប់ពីថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០១៨** តទៅ ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ុនផេង ពុធវិសាល** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ២- ឯកឧត្តម **ព្រំ ពិសុទ្ធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៣- ឯកឧត្តម **ពិន សារ៉ាត** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៤- លោក **ភា វណ្ណា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៥- ឯកឧត្តម **ប៉ែន ដារ៉ារ័ត្ន** | ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៨

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

០៧៩៧.១៥០៣.២៧៤

លេខៈ២៩១ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃសុក្រ ៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៨/២៧៧

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** ដំឡើងឋានន្តរស័ក្តិ ដល់ នាយទាហាន(នារី) ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី **អ៊ុក សុភា** អត្តលេខ ០២៦៤៦១
២-ឧត្តមសេនីយ៍ត្រី **ច័ន្ទ មុនី** អត្តលេខ ០០១៨៦០
៣-ឧត្តមសេនីយ៍ត្រី **ស៊ុន ថាវី** អត្តលេខ ០១៦៤៥៣
៤-ឧត្តមសេនីយ៍ត្រី **ហ៊ាង គីមឆូ** អត្តលេខ ០០០៦៥៦
៥-ឧត្តមសេនីយ៍ត្រី **ប្រាក់ ស្រីពៅ** អត្តលេខ ១១០៧៩៨
៦-ឧត្តមសេនីយ៍ត្រី **ហ៊ួន រ៉ាវី** អត្តលេខ ០៦៣៧៨១
៧-ឧត្តមសេនីយ៍ត្រី **ម៉ា ណាវី** អត្តលេខ ០០៤២៣៤
៨-ឧត្តមសេនីយ៍ត្រី **ផូរ ពិទូរ** អត្តលេខ ០១៤៤៨៤
៩-ឧត្តមសេនីយ៍ត្រី **លឹម ពេជ្រសារ** អត្តលេខ ០២៤៧៨៧
១០-ឧត្តមសេនីយ៍ត្រី **គឹម ចុឌ្ឍាវី** អត្តលេខ ០២៤៨០៨
១១-ឧត្តមសេនីយ៍ត្រី **តូច នារីវឌ្ឍនា** អត្តលេខ ០១៣៩៩១
១២-ឧត្តមសេនីយ៍ត្រី **ម៉ែន ភានីកា** អត្តលេខ ០១៩៧២៨

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **ដួង** | **ចន្ណា** | អត្តលេខ ០៥០៨៥៤ |
| ២-វរសេនីយ៍ឯក | **គឹម** | **សុផល** | អត្តលេខ ០២៦៩៦២ |
| ៣-វរសេនីយ៍ឯក | **អ៊ី** | **ណារីនេត** | អត្តលេខ ០៦៧៨២១ |
| ៤-វរសេនីយ៍ឯក | **ទ៉ា** | **កាន់នីកា** | អត្តលេខ ០៣៥៨៥៩ |
| ៥-វរសេនីយ៍ឯក | **តាំង** | **ផល្លី** | អត្តលេខ ០២៥៧១៨ |

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៨

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បរស.១៥០៣.២៧៥

លេខ: ២៩៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃសុក្រ ៨កើត ខែផល្គុន ឆ្នាំរកា ឆស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ...២៥៧...អនក្រ.បក

**អនុក្រឹត្យ**

**ស្ដីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.**_

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ២ ៦៦១ ០០០ ០០០ រៀល (ពីរប៊ីលានប្រាំមួយរយហុកសិបមួយលានរៀលគត់) ក្នុងនោះ ពីផ្នែកអប់រំ ជំពូក ៦០ (ការទិញ) ចំនួន ២ ៤១៣ ០០០ ០០០ រៀល ពីផ្នែកឧត្តមសិក្សា ជំពូក ៦០(ការទិញ) ចំនួន ១៤៣ ០០០ ០០០ រៀល និងពីផ្នែកយុវជន និងកីឡា ជំពូក ៦០ (ការទិញ) ចំនួន ១០៥ ០០០ ០០០ រៀល មកផ្នែកអប់រំ ជំពូក ៦១(សេវាកម្ម) ចំនួន ១ ០៩៥ ០០០ ០០០ រៀល និងមកផ្នែកយុវជន ជំពូក ៦២(អត្ថប្រយោជន៍សង្គម) ចំនួន ១ ៥៦៦ ០០០ ០០០ រៀល ជូនក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

**មាត្រា២.**_

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ កើត ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៩ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតមូលនិធិគន្ធបុប្ផាកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងបង្កើត “មូលនិធិគន្ធបុប្ផាកម្ពុជា” សរសេរកាត់ថា “**ម.គ.ក.**” និងមានឈ្មោះជាអក្សរឡាតាំង “ CAMBODIA KANTHA BOPHA FOUNDATION និងសរសេរកាត់ជាអក្សរឡាតាំងថា “CKF ” ដើម្បីកៀរគរអំណោយ ឧបត្ថម្ភធន និងវិភាគទានពីគ្រប់ប្រភពស្របច្បាប់នានា ធានាចីរភាពនៃប្រភពចំណូលសម្រាប់ទ្រទ្រង់ផ្នែកហិរញ្ញវត្ថុចំពោះមន្ទីរពេទ្យគន្ធបុប្ផា ឱ្យអាចដំណើរការជាប្រក្រតី ប្រកបដោយនិរន្តរភាពបម្រើដល់គោលនយោបាយលើកកម្ពស់សុខុមាលភាពសង្គម របស់រាជរដ្ឋាភិបាលកម្ពុជា និងធានាឱ្យមន្ទីរពេទ្យគន្ធបុប្ផាគោរពបាននូវគោលការណ៍ទាំង ៤គឺ÷

- រក្សាកម្រិតបៀវត្សរ៍សមរម្យសម្រាប់បុគ្គលិក ដើម្បីធានាបានវិន័យ និងការយកចិត្តទុកដាក់របស់បុគ្គលិក
- រក្សាប្រព័ន្ធប្រតិបត្តិការ និងការគ្រប់គ្រងពិសេសសម្រាប់មន្ទីរពេទ្យនេះ
- បន្តអនុវត្តគោលការណ៍មិនយកកម្រៃសេវាសម្រាប់ប្រជាជនគ្រប់គ្នា និង
- បន្តរក្សា និងពង្រឹងគុណភាពដែលមានស្រាប់។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅ កំណត់អំពីលក្ខខណ្ឌ បែបបទ និង នីតិវិធី ក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅនៃ **ម.គ.ក.**

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ មូលនិធិគន្ធបុប្ផាកម្ពុជា ។

**មាត្រា៤.-**

បច្ចេកសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចបានកំណត់ខាងក្រោម÷

- **បរធន** សំដៅដល់ទ្រព្យសម្បត្តិ ឬមូលនិធិ ដែលបានផ្ទេរទៅឱ្យបរធនបាលគ្រប់គ្រង និងចាត់ចែង សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។

- **បរធនបាល** សំដៅដល់បុគ្គល ដែលទទួលសិទ្ធិគ្រប់គ្រង និងចាត់ចែងបរធន ពីបរធនបាលទាយក សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។
- **បរធនបាលទាយក** សំដៅដល់បុគ្គលដែលបង្កើត និងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្តល់ទ្រព្យសម្បត្តិ ឬមូលនិធិដំបូងទៅក្នុងបរធនបាលកិច្ច។
- **បរធនបាលកិច្ច** សំដៅដល់កិច្ចការគ្រប់គ្រង និងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាល-ទាយក សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ២
## អត្តសញ្ញាណ ប្រភពធនធាន និងបរធនបាលកិច្ច នៃ ម.គ.ភ.
### ផ្នែកទី១
### អត្តសញ្ញាណ និងប្រភពធនធាន

**មាត្រា ៥.-**

**ម.គ.ភ.** ជាបរធនបាលកិច្ច ដែលបង្កើតឡើង ដើម្បីស្វែងរកជំនួយមនុស្សធម៌ មិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ សាសនា និន្នាការនយោបាយ និងបម្រើឱ្យផលប្រយោជន៍សាធារណៈ។

**ម.គ.ភ.** អាចមានធនធានពីប្រភពដូចតទៅ ÷

- វិភាគទានដំបូង ជារបស់រាជរដ្ឋាភិបាលកម្ពុជា
- វិភាគទានប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ដែលបានគ្រោងក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល
- កម្រៃពីថ្លៃសំបុត្រចូលទស្សនាតំបន់រមណីយដ្ឋានអង្គរ និង
- អំណោយ និងវិភាគទានសប្បុរសធម៌ ពីគ្រប់ប្រភពស្របច្បាប់ផ្សេងៗ ទៀត។

### ផ្នែកទី២
### បរធនបាលកិច្ច នៃ ម.គ.ភ.

**មាត្រា៦.-**

បរធនបាលទាយក គឺជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាប្រធានកិត្តិយសនៃ ម.គ.ភ. ។

បរធនបាលកិច្ចត្រូវស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់ក្រុមប្រឹក្សាបរធនបាល **ម.គ.ភ.**។

**មាត្រា៧.-**

**ម.គ.ភ.** មានរូបសញ្ញា និងត្រាដោយឡែក ក្នុងការបំពេញភារកិច្ចរបស់ខ្លួន តាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល **ម.គ.ភ.**។

**ម.គ.ភ.** មានទីស្នាក់ការកណ្តាលនៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថិតនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលអនាគត ជាកម្មវត្ថុនៃការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល **ម.គ.ភ.** ។

## ជំពូកទី៣

## សមាជិកភាព នៃ ម.គ.ភ.

**មាត្រា៨.-**

**ម.គ.ភ.** អាចមានសមាជិកតាមការចាំបាច់។ ការសម្រេចបញ្ចូលសមាជិកភាព ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល ផ្អែកតាមលក្ខណៈសម្បត្តិនៃបុគ្គលនីមួយៗ។

**មាត្រា៩.-**

សមាជិក **ម.គ.ភ.** មានបីប្រភេទ÷

១. សមាជិកស្ថាបនិក

២. សមាជិកកិត្តិយស និង

៣. សមាជិកគាំទ្រ

ផ្អែកតាមសំណើរបស់សាមីជន សមាជិកកិត្តិយស និង សមាជិកគាំទ្រ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់អាចក្លាយជាសមាជិកក្រុមប្រឹក្សាបរធនបាល តាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល **ម.គ.ភ.**។

លក្ខខណ្ឌនៃការទទួលបាន និងការបញ្ចប់នូវសមាជិកភាព ព្រមទាំងគុណវុឌ្ឍិសម្រាប់ក្លាយជាសមាជិកក្រុមប្រឹក្សាបរធនបាល នឹងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល **ម.គ.ភ.**។

## ជំពូកទី៤

## សមាសភាព រចនាសម្ព័ន្ធ តួនាទី និងសិទ្ធិអំណាច

## ផ្នែកទី១

## ក្រុមប្រឹក្សាបរធនបាល

**មាត្រា១០.-**

ក្រុមប្រឹក្សាបរធនបាល មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៣. | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៥. | អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. | ប្រធានមន្ទីរពេទ្យគន្ធបុប្ផាភ្នំពេញ | សមាជិក |
| ៧. | ប្រធានមន្ទីរពេទ្យជ័យវរ្ម័នទី៧ | សមាជិក |

សមាសភាពជាក់ស្តែងរបស់ក្រុមប្រឹក្សាបរធនបាល ត្រូវតែងតាំង និងផ្លាស់ប្តូរដោយអនុក្រឹត្យ សម្រាប់អាណត្តិ ៣ (បី) ឆ្នាំ និងអាចបន្តទៀតបាន តាមសំណើរបស់ក្រសួងស្ថាប័ន ដែលសមាជិកនោះជាតំណាង។

**មាត្រា១១.-**

ក្រុមប្រឹក្សាបរធនបាល មានតួនាទី សិទ្ធិ និងអំណាច ដូចខាងក្រោម ÷

- ពិនិត្យ និងអនុម័តថវិកាប្រចាំឆ្នាំ និងរបាយការហិរញ្ញវត្ថុ របស់ **ម.គ.ភ.**
- តាមដាន ត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃវឌ្ឍនភាពនៃដំណើរការរបស់ **ម.គ.ភ.**
- ធ្វើការអំពាវនាវ កៀរគរប្រមូលធនធានហិរញ្ញវត្ថុ និងសម្ភារៈនានា ជាសាធារណៈ ពីប្រភពក្នុង និងក្រៅប្រទេស ដើម្បីបម្រើដល់គោលបំណង និងគោលដៅដូចមានចែងក្នុងមាត្រាខាងលើ
- រៀបចំគោលនយោបាយ និងនីតិវិធីផ្តល់ការឧបត្ថម្ភទ្រទ្រង់ដល់មន្ទីរពេទ្យគន្ធបុប្ផា
- គ្រប់គ្រង និងប្រើប្រាស់ថវិកាដែលទទួលបានពីការឧបត្ថម្ភពីគ្រប់ប្រភព ឱ្យមានតម្លាភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដែលទទួលបាននូវជំនឿទុកចិត្តពីសាធារណជន
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគ **ម.គ.ភ.** តាមច្បាប់ជាធរមាន
- សហការជាមួយស្ថាប័ន ឬមូលនិធិនានា រួមទាំង មូលនិធិគន្ធបុប្ផាប្រទេសស្វីស ដើម្បីការរីកចម្រើន និងចីរភាពនៃ **ម.គ.ភ.**
- ដាក់ចេញនូវបែបបទ និងនីតិវិធីចាំបាច់នានាពាក់ព័ន្ធការគ្រប់គ្រង និងដំណើរការនៃ **ម.គ.ភ.**

- បង្កើតគណៈកម្មការ ឬក្រុមការងារ តាមការចាំបាច់ ដើម្បីបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**មាត្រា១២.-**

ដំណើរការការងាររបស់ក្រុមប្រឹក្សាបរធនបាល ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ម.គ.ភ.** ។

**មាត្រា១៣.-**

ក្រុមប្រឹក្សាបរធនបាល នៃ **ម.គ.ភ.** ត្រូវប្រជុំការងារយ៉ាងតិចមួយដង ក្នុងមួយឆ្នាំ ឬ អាចប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាបរធនបាល។ ករណីចាំបាច់ ប្រធានក្រុមប្រឹក្សាបរធនបាលអាចប្រគល់សិទ្ធិឱ្យអនុប្រធានណាម្នាក់ដឹកនាំកិច្ចប្រជុំជំនួស។

កិច្ចប្រជុំក្រុមប្រឹក្សាបរធនបាលអាចដំណើរការបាន លុះត្រាតែមានវត្តមាននៃសមាជិកយ៉ាងតិចពីរភាគបី។

ប្រធានក្រុមប្រឹក្សាបរធនបាល អាចអញ្ជើញតំណាងក្រសួងស្ថាប័ននានា ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាបរធនបាល និង ឥស្សរជននានា ដែលមានបទពិសោធនលើវិស័យវិទ្យាសាស្ត្រសេដ្ឋកិច្ច ហិរញ្ញវត្ថុ សុខាភិបាល សង្គមកិច្ច ឱ្យចូលរួមប្រជុំបាន តែតំណាងទាំងនោះពុំមានសិទ្ធិបោះឆ្នោតឡើយ។

**មាត្រា១៤.-**

ការសម្រេចនានារបស់ក្រុមប្រឹក្សាបរធនបាល អាចទុកជាបានការ លុះត្រាតែមានសំលេងគាំទ្រភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ តម្កល់ទុកនៅទីស្នាក់ការរបស់ **ម.គ.ភ.** និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាបរធនបាលទាំងអស់។

## ផ្នែកទី២

## នាយកប្រតិបត្តិនៃ ម.គ.ភ.

**មាត្រា១៥.-**

**ម.គ.ភ.** មានរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាបរធនបាលជានាយកប្រតិបត្តិ ហើយមានលេខាធិការដ្ឋាន ជាសេនាធិការរដ្ឋបាល និងបច្ចេកទេស។

**មាត្រា១៦.-**

នាយកប្រតិបត្តិនៃ **ម.គ.ភ.** មានភារកិច្ចសម្របសម្រួល និងអនុវត្តការងារ ដូចតទៅ÷

- ត្រួតពិនិត្យលើការរក្សាកំណត់ត្រាហិរញ្ញវត្ថុ ការរៀបចំលិខិតបញ្ជាក់ការទទួល និងការផ្ដល់វិភ័យប័ត្រមូលនិធិ និងលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបសម្រាប់ក្រុមប្រឹក្សាបរធនបាល **ម.គ.ក.**
- សម្របសម្រួលជាមួយក្រសួងសុខាភិបាល និងមន្ទីពេទ្យគន្ធបុប្ផា ក្នុងការផ្សព្វផ្សាយ និងរៀបចំកម្មវិធីផ្សេងៗតាមការចាំបាច់ សំដៅកៀរគរវិភាគទានពីសប្បុរសជន និង
- អនុវត្តភារកិច្ចដទៃទៀតតាមការណែនាំរបស់ក្រុមប្រឹក្សាបរធនបាល **ម.គ.ក.** ។

## ផ្នែកទី ៣

## លេខាធិការដ្ឋាននៃ ម.គ.ក

**មាត្រា១៧.-**

សមាសភាពជាក់ស្ដែងនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាបរធនបាល។

**មាត្រា១៨.-**

លេខាធិការដ្ឋានមានភារកិច្ចជាអាទិ៍÷

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាបរធនបាល
- រៀបចំផែនការថវិកាប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ **ម.គ.ក.** ដើម្បីដាក់ជូនក្រុមប្រឹក្សាបរធនបាល ពិនិត្យ និងសម្រេច និង
| ២៦២-នាយចំណង់ | អ៊ីន ម៉ិនថៃ | អត្តលេខ ១០៥៣៦៣ | ជំនួយការរថយន្តម៉ាស៊ីន ការិយាល័យ បច្ចេកទេស នៃសាកលវិទ្យាល័យការពារជាតិ |
| ២៦៣-នាយចំណង់ | ម៉ាត់ ហ្សារីដា | អត្តលេខ ២០៦៣៥៧ | ជំនួយការឯកសារចេញចូល លេខាធិការដ្ឋាន មហាវិទ្យាល័យព័ត៌មានវិទ្យា និងភស្តុភារ ហិរញ្ញវត្ថុយោធា នៃសាកលវិទ្យាល័យការពារជាតិ |
| ២៦៤-ព្រឹន្ទបាលឯក | ស្វាយ ចិត្រា | អត្តលេខ១៩១៩២៨ | កីឡាករអត្តពលកម្ម មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |
| ២៦៥-ព្រឹន្ទបាលឯក | ផាត់ ឡេង | អត្តលេខ១៩១៩៤៧ | បើកបរ មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |
| ២៦៦-ព្រឹន្ទបាលទោ | សួន ទ្រី | អត្តលេខ១០៤៥១៩ | តន្ត្រីករ មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |
| ២៦៧-ព្រឹន្ទបាលទោ | សាន ឡុន | អត្តលេខ១០៧៣២៤ | តន្ត្រីករ មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |
| ២៦៨-ព្រឹន្ទបាលទោ | គ្រាប់ ត្រឹង | អត្តលេខ២២០៣១៨ | តន្ត្រីករ មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |
| ២៦៩-ព្រឹន្ទបាលទោ | ថាំង ចិបុល | អត្តលេខ២១៦២៨៩ | ជំនួយការ ការិយាល័យផែនការ មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |
| ២៧០-ពលបាលត្រី | ស៊ិន វឌ្ឍមុន្នី | អត្តលេខ២១៦៣១៧ | កីឡាករ ប៉េតង់ មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |
| ២៧១-ពលបាលត្រី | ញ៉ឹក សុគន្ធី | អត្តលេខ១៩១៩៤៥ | ជំនួយការ ការិយាល័យបុគ្គលិក មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |
| ២៧២-នាយឯក | អុន ទេវថៃ | អត្តលេខ១៩១៩២៧ | ជំនួយការ ការិយាល័យទំនាក់ទំនងសាធារណៈ មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |
| ២៧៣-នាយទោ | នេត ទាសនា | អត្តលេខ១៩១៩៥៥ | កីឡាករបាល់ទាត់ មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ថ្ងៃ ១១ កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧ សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការសម្រាប់កំណត់សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ហ្វ្រេកង់ស៍ ៧០០ MHz

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នា១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការដើម្បីសិក្សាស្ដីពីស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់ហ្វ្រេកង់ស៍ ៧០០ MHz សម្រាប់កំណត់សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ហ្វ្រេកង់ស៍ ៧០០ MHz នេះ។

**ប្រការ២.-**

គណៈកម្មការមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ប្រធាន |
| ២. ឯកឧត្តម **សារ៉ាត់ ខាន់** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៣. ឯកឧត្តម **សុខ ពុទ្ធិវុធ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៤. ឯកឧត្តម **អៀង ស៊ុនលី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. ឯកឧត្តម **ជា មានិត** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

៦. ឯកឧត្តម **ញឹក កោសល្យវិទ្យា** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៧. ឯកឧត្តម **ផុស សុវណ្ណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន សមាជិក ។

**ប្រការ៣.**_

គណៈកម្មការនេះមានតួនាទី និងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ដឹកនាំនិងសម្របសម្រួលលើការងាររៀបចំការសិក្សាស្តីពីស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់ប្រេកង់ស៍ ៧០០ MHz ឲ្យទទួលបានជោគជ័យ
- ប្រមូលធាតុចូលទាំងអស់ពាក់ព័ន្ធនឹងការបែងចែក និងការប្រើប្រាស់ប្រេកង់ស៍ ៧០០ MHz ពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- ដឹកនាំរៀបចំសិក្ខាសាលាថ្នាក់ជាតិ ដោយសហការជាមួយនឹងសហភាពទូរគមនាគមន៍អន្តរជាតិ ដៃគូសន្ទនា និងដៃគូអភិវឌ្ឍពាក់ព័ន្ធ ព្រមទាំងវិស័យឯកជន ដើម្បីធានាអនុលោមភាពរបស់កម្ពុជាជាមួយនឹងសុខដុមនីយកម្មតំបន់និងពិភពលោក លើសមត្ថកិច្ចគ្រប់គ្រងនិងការប្រើប្រាស់ប្រេកង់ស៍ ៧០០ MH និងដើម្បីទទួលបាននូវការចូលរួមចែករំលែកអំពីឧត្តមានុវត្តន៍លើសមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ប្រេកង់ស៍ ៧០០ MHz នៅក្នុងតំបន់ និងពិភពលោក
- ដឹកនាំរៀបចំនិងកំណត់សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ប្រេកង់ស៍ ៧០០ MHz
- គណៈកម្មការអាចសហការ ឬស្នើឲ្យមានកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍតាមតម្រូវការជាក់ស្តែង
- រៀបចំនិងដាក់ជូនលទ្ធផលស្តីពីការសិក្សានិងការកំណត់សមត្ថកិច្ច និងការប្រើប្រាស់ប្រេកង់ស៍ ៧០០ MHz ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលើកិច្ចការនេះនឹងត្រូវបានប្រើប្រាស់ដើម្បីធ្វើជាមូលដ្ឋានបន្ថែមនៃការរៀបចំសេចក្តីព្រាងច្បាប់គមនាគមន៍វិទ្យុ ។

**ប្រការ៤.**_

គណៈកម្មការមានសិទ្ធិអញ្ជើញមន្ត្រីជំនាញជាតិ និងអន្តរជាតិមកចូលរួមផ្តល់យោបល់បន្ថែមលើប្រធានបទនេះ ហើយអាចចាត់តាំងក្រុមការងារតាមការចាំបាច់ ។

**ប្រការ៥.**_

គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ៦.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៧.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃពុធ ១៣ រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៤ សសរ

## សេចក្ដីសម្រេច
## ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២១៣ / ១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤១៦ / ៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

### សម្រេច

**ប្រការ ១៖** ត្រូវបានផ្ទេរសិទ្ធិជូនសម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជានាយករដ្ឋមន្ត្រីស្ដីទីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជំនួសសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលពិសេស **អាស៊ាន-អូស្ត្រាលី** នៅទីក្រុងស៊ីដនីនៃប្រទេសអូស្ត្រាលី ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃ ១៤ រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៨ រហូតដល់ពេលសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងសម្ដេចក្រឡាហោម **ស ខេង** ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃព្រហស្បតិ៍ ១៤ រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១*
*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣១ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតវិញ្ញាបនប័ត្រប្រធានសម្រាប់ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/១៣៩៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៥៤២ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ៩៧៥ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និង នីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១៥៦៩ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក៦០“ការទិញ” ជំពូក៦១“សេវាកម្ម” នៅអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២ ._**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៥ រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានរតនាគារជាតិ

## តារាងឧបសម្ព័ន្ធវដ្ដទៀងបុរេប្រទានថវិកាកម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ ២០១៨
## របស់អគ្គនាយកដ្ឋានរតនាគារជាតិ

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន វដ្ដទៀងបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ដុំបង្គ្រប់ វដ្ដទៀងបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ |
| | | | **សរុបរួម** | 7,916,000,000.0 | 6,581,500,000.0 | 2,217,828,500.0 | 4,363,671,500.0 | 554,457,125.0 | 33.7% |
| 60 | | | ការទិញ | 4,254,300,000.0 | 3,315,400,000.0 | 428,170,000.0 | 2,887,230,000.0 | 107,042,500.0 | 12.9% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 607,100,000.0 | 607,100,000.0 | 197,080,000.0 | 410,020,000.0 | 49,270,000.0 | 32.5% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 165,400,000.0 | 165,400,000.0 | 65,400,000.0 | 100,000,000.0 | 16,350,000.0 | 39.5% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ | 69,300,000.0 | 69,300,000.0 | 4,300,000.0 | 65,000,000.0 | 1,075,000.0 | 6.2% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈ ឧបករណ៍ | 252,400,000.0 | 252,400,000.0 | 103,380,000.0 | 149,020,000.0 | 25,845,000.0 | 41.0% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 120,000,000.0 | 120,000,000.0 | 24,000,000.0 | 96,000,000.0 | 6,000,000.0 | 20.0% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 1,100,900,000.0 | 1,080,900,000.0 | 156,690,000.0 | 924,210,000.0 | 39,172,500.0 | 14.5% |
| | | 60021 | សម្ភារៈការិយាល័យ | 1,072,900,000.0 | 1,072,900,000.0 | 148,690,000.0 | 924,210,000.0 | 37,172,500.0 | 13.9% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 20,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |
| | | 60023 | ការបោះពុម្ព | 8,000,000.0 | 8,000,000.0 | 8,000,000.0 | 0.0 | 2,000,000.0 | 100.0% |
| | 6004 | | សំលៀកបំពាក់និងការតុបតែង | 12,000,000.0 | 12,000,000.0 | 12,000,000.0 | 0.0 | 3,000,000.0 | 100.0% |
| | | 60048 | សំលៀកបំពាក់និងការតុបតែងផ្សេងៗ | 12,000,000.0 | 12,000,000.0 | 12,000,000.0 | 0.0 | 3,000,000.0 | 100.0% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 1,623,600,000.0 | 1,615,400,000.0 | 62,400,000.0 | 1,553,000,000.0 | 15,600,000.0 | 3.9% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 339,200,000.0 | 339,200,000.0 | 15,000,000.0 | 324,200,000.0 | 3,750,000.0 | 4.4% |
| | | 60052 | សង្ហារឹម | 233,600,000.0 | 233,600,000.0 | 14,400,000.0 | 219,200,000.0 | 3,600,000.0 | 6.2% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 76,600,000.0 | 76,600,000.0 | 14,600,000.0 | 62,000,000.0 | 3,650,000.0 | 19.1% |
| | | 60054 | សម្ភារៈនិងឧបករណ៍ដឹកជញ្ជូន | 8,200,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |
| | | 60055 | សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា | 966,000,000.0 | 966,000,000.0 | 18,400,000.0 | 947,600,000.0 | 4,600,000.0 | 1.9% |
| | 6006 | | ថាមពលនិងទឹក | 910,700,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |
| | | 60061 | អគ្គិសនី | 811,400,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ដុំបង្កើល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២-៣ | ៥= ៣/ ៤ដុំ | ៦= ៣/ ២ |
| | | 60062 | ទឹក | 99.300,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |
| 61 | | | សេវាកម្ម | 3,661,700,000.0 | 3,266,100,000.0 | 1,789,658,500.0 | 1,476,441,500.0 | 447,414,625.0 | 54.8% |
| | 6103 | | ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) ក្នុងនិងក្រៅប្រទេស | 88,800,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |
| | | 61031 | ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) ក្នុងប្រទេស | 88.800,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស | 96,400,000.0 | 96,400,000.0 | 96,400,000.0 | 0.0 | 24,100,000.0 | 100.0% |
| | | 61041 | សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស | 96.400,000.0 | 96,400,000.0 | 96.400,000.0 | 0.0 | 24,100,000.0 | 100.0% |
| | 6105 | | ការថែទាំនិងជួសជុល | 1,499,300,000.0 | 1,499,300,000.0 | 357,610,100.0 | 1,141,689,900.0 | 89,402,525.0 | 23.9% |
| | | 61052 | ការថែទាំ ជួសជុលអាគារផ្សេងៗ និងប្រាសាទ | 588.300,000.0 | 588,300,000.0 | 80.790,100.0 | 507,509,900.0 | 20,197,525.0 | 13.7% |
| | | 61053 | ការថែទាំនិងជួសជុល ផ្លូវ ផ្លូវលំ ស្ពាន និងលូ | 172,000,000.0 | 172,000,000.0 | 72,000,000.0 | 100,000,000.0 | 18,000,000.0 | 41.9% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 323.200,000.0 | 323,200,000.0 | 43.020,000.0 | 280,180,000.0 | 10,755,000.0 | 13.3% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 48,000,000.0 | 48,000,000.0 | 48,000,000.0 | 0.0 | 12,000,000.0 | 100.0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈនិងឧបករណ៍បច្ចេកទេស | 367.800,000.0 | 367,800,000.0 | 113.800,000.0 | 254,000,000.0 | 28,450,000.0 | 30.9% |
| | 6107 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយ | 38,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |
| | | 61073 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 38.000,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |
| | 6108 | | សោហ៊ុយដឹកជញ្ជូន | 9,600,000.0 | 9,600,000.0 | 9,600,000.0 | 0.0 | 2,400,000.0 | 100.0% |
| | | 61081 | សម្ភារៈនិងទំនិញ | 9.600,000.0 | 9,600,000.0 | 9.600,000.0 | 0.0 | 2,400,000.0 | 100.0% |
| | 6109 | | បុគ្គលិកខាងក្រៅ | 7,200,000.0 | 7,200,000.0 | 7,200,000.0 | 0.0 | 1,800,000.0 | 100.0% |
| | | 61098 | បុគ្គលិកខាងក្រៅផ្សេងៗ | 7,200,000.0 | 7,200,000.0 | 7,200,000.0 | 0.0 | 1,800,000.0 | 100.0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 320,600,000.0 | 320,600,000.0 | 240,600,000.0 | 80,000,000.0 | 60,150,000.0 | 75.0% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 80.000,000.0 | 80,000,000.0 | 80,000,000.0 | 0.0 | 20,000,000.0 | 100.0% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 30.000,000.0 | 30,000,000.0 | 30,000,000.0 | 0.0 | 7,500,000.0 | 100.0% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 70,500,000.0 | 70,500,000.0 | 70.500,000.0 | 0.0 | 17,625,000.0 | 100.0% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 100.000,000.0 | 100,000,000.0 | 20.000,000.0 | 80,000,000.0 | 5,000,000.0 | 20.0% |
| | | 61108 | សោហ៊ុយទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយផ្សេងៗ | 40.100,000.0 | 40,100,000.0 | 40,100,000.0 | 0.0 | 10,025,000.0 | 100.0% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 1,200,300,000.0 | 1,200,300,000.0 | 951,668,400.0 | 248,631,600.0 | 237,917,100.0 | 79.3% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 254.600,000.0 | 254,600,000.0 | 220.244,400.0 | 34,355,600.0 | 55,061,100.0 | 86.5% |
| | | 61122 | សោហ៊ុយបេសកកម្ម | 142.600,000.0 | 142,600,000.0 | 123.604.000.0 | 18,996,000.0 | 30,901,000.0 | 86.7% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 803.100,000.0 | 803,100,000.0 | 607.820,000.0 | 195,280,000.0 | 151,955,000.0 | 75.7% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 50,100,000.0 | 50,100,000.0 | 43,980,000.0 | 6,120,000.0 | 10,995,000.0 | 87.8% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 9.600,000.0 | 9,600,000.0 | 9,000,000.0 | 600,000.0 | 2,250,000.0 | 93.8% |
| | | 61132 | សោហ៊ុយបេសកកម្ម | 10.500,000.0 | 10,500,000.0 | 9.140,000.0 | 1,360,000.0 | 2,285,000.0 | 87.0% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន១២ដុំបង្គិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២-៣ | ៥= ៣/ ៤ដុំ | ៦= ៣/ ២ |
| | | 61133 | សោហ៊ុយស្នាក់នៅ | 30,000,000.0 | 30,000,000.0 | 25,840,000.0 | 4,160,000.0 | 6,460,000.0 | 86.1% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 268,800,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 268,800,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0% |
| | 6198 | | សេវាកម្មផ្សេងៗទៀត | 82,600,000.0 | 82,600,000.0 | 82,600,000.0 | 0.0 | 20,650,000.0 | 100.0% |
| | | 61981 | សេវាកម្មផ្សេងៗទៀត | 82,600,000.0 | 82,600,000.0 | 82,600,000.0 | 0.0 | 20,650,000.0 | 100.0% |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ............ ខែ............ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ២០១
ជ. ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ
**អគ្គនាយករង**

**មុំ ញ៉ា បានសុវណ្ណអាទិត្យាស៊ីលា**

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ............ ខែ............ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ២០១
ជ. ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា

**គីម ចំរើន**

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ............ ខែ............ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ២០១៧
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

**បណ្ឌិត ឆាយ ម៉ិនតុន្ត្រាធុជ**

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ...... ឆ្នាំ២០១៧
រដ្ឋទេយ្យករបុរេប្រទាន

**វ៉ា សុវី**

បានឃើញ និងឯកភាព
ថ្ងៃ............ ខែ............ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញភ្នំពេញ, ថ្ងៃទី ០៥ ខែ...... ឆ្នាំ២០១៨
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៤៣៧៣ ឧស.ក.ក.ជ.ក.០៥

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១៧

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតសាខារោងចក្រ ផលិតស្លាកសម្លៀកបំពាក់គ្រប់ប្រភេទ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន ហ្គ័នយ៉ាង លេបឺល (ខេមបូឌា) អិលធីឌី ។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ហ្គ័នយ៉ាង លេបឺល (ខេមបូឌា) អិលធីឌី (GUANYANG LABEL (CAMBODIA) LTD.) តំណាងដោយ លោកស្រី **GUO JIALIN** បង្កើតសាខារោងចក្រ ផលិតស្លាកសញ្ញាសម្លៀកបំពាក់គ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅ អគារលេខ៣ និង៣A សួនឧស្សាហកម្មកាណាឌីយ៉ា ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| ស្លាកសញ្ញាសម្លៀកបំពាក់ | ១៣៩៩ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រផលិតស្លាកសញ្ញាសម្លៀកបំពាក់ ហ្គ័នយ៉ាង លេបឺល (ខេមបូឌា) អិលធីឌី សាខាទី១"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៧៤ ឧស.ក.ឧ.ស.ក.០៩

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១៧

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រកែច្នៃដែកថែប ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ របស់ ក្រុមហ៊ុន ម៉ាប៊ូជី (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១ៈ** អនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាប៊ូជី (ខេមបូឌា) ឯ.ក (MABUCHI (CAMBODIA) CO., LTD.) តំណាងដោយលោក **MIKIO SAKAMOTO** បង្កើតរោងចក្រកែច្នៃដែកថែប ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសសានកូប៉ោយប៉ែត (ភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ)។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១- គ្រោង និងទូរដាក់ឯកសារពីដែក | ២៤១០ |
| ២- គ្រោងដាក់សម្ភារៈ និងឧបករណ៍ប្រើប្រាស់ពីដែក | ២៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រកែច្នៃដែកថែប ម៉ាប៊ុជី (ខេមបូឌា) ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួង ឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបន្ទាយមានជ័យ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តបន្ទាយមានជ័យ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបន្ទាយមានជ័យ "ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៧៤ ឧស.ករ.ក.០៩

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៧

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន អេវើ-ស៊ីនើជី (ខេមបូឌា) ហ្គាមិន ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អេវើ-ស៊ីនើជី (ខេមបូឌា) ហ្គាមិន ឯ.ក (EVER-SYNERGY (CAMBODIA) GARMENTS CO., LTD.) តំណាងដោយ លោក CHEN YONG បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រកាត់ដេរសម្លៀកបំពាក់ អេវើ-ស៊ីនើជី (ខេមបូឌា) ហ្គាម៉ិន "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១១</u>៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១២</u>៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**<u>ប្រការ១៣</u>៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**<u>ប្រការ១៤</u>** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**<u>ប្រការ១៥</u>៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**<u>ចម្លងជូន៖</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៧៧ ឧស.ក.ស.ក.ពវឆ

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១៧

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រផលិត និងផ្គុំខ្សែអំពូលភ្លើងព័ណលំអគ្រប់ប្រភេទ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន ឡៃថ៍ វីល ដេខ័ររេសិន (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ឡៃថ៍ វីល ដេខ័ររេសិន (ខេមបូឌា) ឯ.ក (LIGHT WHEEL DECORATION (CAMBODIA) CO., LTD.) តំណាងដោយ លោក LEE, CHUAN-YANG បង្កើតរោងចក្រផលិត និងផ្គុំខ្សែអំពូលភ្លើងព័ណលំអគ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៥១ ភូមិដំណាក់ព្រីង ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្ដាល។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ខ្សែអំពូលភ្លើងពណ៌លំអគ្រប់ប្រភេទ | ២៧៤០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រផលិត និងផ្គុំខ្សែអំពូលភ្លើងព៌ណលំអគ្រប់ប្រភេទ ឡៃច័ រីលដេខ័រសេិន (ខេមបូឌា) ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឋ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលាខេត្តកណ្តាល
- -មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី